ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
លេខ :...៧៨៣.អ.ស.ល

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៨

## សេចក្តីជូនដំណឹង

សូមទូលថ្វាយ និងគោរពជំរាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាមន្ត្រីរាជការគ្រប់ស្ថាប័ន ក្រសួង មន្ទីរ អង្គការ សមាគមន៍ និងប្រជាពលរដ្ឋទាំងអស់ សូមទ្រង់ជ្រាប និងមេត្តាជ្រាបថា :

ដើម្បីអនុវត្តអោយបានត្រឹមត្រូវ តាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សំដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលបច្ចុប្បន្នបាននិងកំពុងកើតឡើង ភាគច្រើនដល់អ្នកជិះទោចក្រយានយន្តដែលងាយទទួលរងគ្រោះត្រង់ក្បាលបណ្តាលអោយបាត់បង់ជីវិត ឬ របួសធ្ងន់ធ្ងរដល់ពិការភាពបាត់បង់ពលកម្ម ។

អគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញបទបញ្ជាដល់នគរបាលចរាចរណ៍គ្រប់ខេត្ត-ក្រុង ចាប់ផ្តើមធ្វើការត្រួតពិនិត្យ ផាកពិន័យតាម**ជំពូក១០** នៃច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក **ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៩ លើករណី មិនពាក់មួកសុវត្ថិភាព ក្នុងពេលបើកបរទោចក្រយានយន្ត និងត្រីចក្រយានយន្ត** ។

អាស្រ័យហេតុនេះ សំណូមពរដល់ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងប្រជាពលរដ្ឋ ពិសេសមាតាបិតាគ្រប់គ្រួសារ សូមមេត្តាជួយជំរុញដល់មន្ត្រីក្រោមឱវាទ ឬ បុត្រធីតា គប្បីពាក់មួកសុវត្ថិភាពគ្រប់ៗគ្នា ក្នុងពេលធ្វើដំណើរដោយទោចក្រយានយន្ត និងត្រីចក្រយានយន្ត ។ មួកសុវត្ថិភាពពិតជាមានគុណប្រយោជន៍អាចជួយសង្គ្រោះជីវិត ឬ សំរាលភាពរងគ្រោះពីគ្រោះថ្នាក់ចរាចរណ៍ជាយថាហេតុណាមួយ ដែលកើតឡើងក្នុងពេលធ្វើដំណើរ ។

អគ្គស្នងការដ្ឋាននគរបាលជាតិ សង្ឃឹមទុកជាមុនលើស្មារតីចូលរួមសហការប្រតិបត្តិច្បាប់ ពីសំណាក់ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និង ប្រជាពលរដ្ឋទាំងអស់ ដើម្បីនាំមកនូវសុវត្ថិភាព និងសុភមង្គល ដល់យើងទាំងអស់គ្នា ។

អគ្គស្នងការនគរបាលជាតិ

នាយឧត្តមសេនីយ៍.ហុក.ឡុងឌី

**ចំលងជូន**

-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
" ដើម្បីជូនជ្រាប "
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង
" ដើម្បីផ្សព្វផ្សាយ និងចូលរួមអនុវត្ត "
-គ្រប់ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង
" ដើម្បីអនុវត្ត "